**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ២៧៥
ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៨

<u>**សាលដីកា**</u>
លេខៈ១៤៣
ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............. ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ............. ជាចៅក្រម

<u>**ក្រឡាបញ្ជី**</u>

-កញ្ញា ................

<u>**តំណាងមហាអយ្យការ**</u>

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧៦៣ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សស ភេទប្រុសអាយុ៥០ឆ្នាំជាតិខ្មែរ ទីលំនៅផ្ទះលេខ៥៦ ក្រុម៣៦ សង្កាត់បឹងកេងកង២ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

ឈ្មោះ ទសប ភេទស្រីអាយុ៤៧ ជាតិខ្មែរ មុខរបរមេផ្ទះទីលំនៅផ្ទះលេខ២២៥ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ សស ភេទស្រីអាយុ៥៨ឆ្នាំ ជាតិខ្មែរទីលំនៅភូមិជ្រោយដង ឃុំសំរោងធំស្រុកកៀនស្វាយ ខេត្តកណ្តាល ។

<u>**កម្មវត្ថុបណ្តឹង**</u> ប្តឹងសុំបែងចែកដីមរតក

បានឃើញបណ្តឹងសាទុក្ខលេខ៦២ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៨ របស់ឈ្មោះ ទសប និងឈ្មោះ សស ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១៦ ០២ ៩៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៧៥ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០១-០៨-៩៥ របស់ដើមចោទថា ខ្លួនប្ដឹងទាមទារកេរ្ដិ៍មរតកពីចុងចម្លើយឈ្មោះ សស ដោយហេតុថា ដីនេះឪពុកឈ្មោះ សអ បានបែងចែកឲ្យកូនតាមចំណែករៀងៗខ្លួនតាំងពីគាត់នៅរស់ដោយមានរដ្ឋអំណាចដឹងឮត្រឹមត្រូវ ។ ក្រោយពីឪពុកស្លាប់បងបង្កើតឈ្មោះ សស បានយកដីនេះទាំងអស់ធ្វើជាកម្មសិទ្ធិដោយមិនព្រមបែងចែកឲ្យបងប្អូនខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៦(ក) ចុះថ្ងៃទី០៦-០៣-៩៦ របស់តុលាការ ខេត្តកណ្ដាលបានសម្រេចសេចក្ដីចំពោះមុខគូក្ដី ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១- ទទួលបណ្ដឹងសុំបែងចែកមរតករបស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- សម្រេចបែងចែកមរតករបស់ខ្មោចឈ្មោះ សអ ឲ្យសហព័ន្ធ និងទាយាទតាមចំណែកដូចខាងក្រោម :

ក- នន កើតជាប្រពន្ធត្រូវបាន១៦%នៃទ្រព្យដែលជាមរតក ។

ខ- ទសប ជាកូនប្រសារត្រូវបាន១៦% នៃចំនួនទ្រព្យដែលជាមរតកជាចំណែករបស់ប្ដី ឈ្មោះ សអ ( ស្លាប់ ) ។

គ- នាង សស ជាកូនទី២ ត្រូវបាន២០%នៃចំនួនទ្រព្យដែលជាមរតក ។

ឃ-នាង ឈផល ជាចៅត្រូវបាន១៦% នៃចំនួនទ្រព្យដែលជាមរតកជាចំណែករបស់ម្ដាយឈ្មោះ សស ( ស្លាប់ ) ។

ង- ឈ្មោះ សស ត្រូវបាន១៦% នៃចំនួនទ្រព្យដែលជាមរតក ។

ច- ឈ្មោះ សស ត្រូវបាន១៦% នៃចំនួនទ្រព្យដែលជាមរតក ។

៣- បង្គាប់ឲ្យនាង សស បង់ប្រាក់ប្រដាប់ក្ដីចំនួន៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់រួចហើយ ហើយឲ្យឈ្មោះនេះសងទៅដើមចោទវិញ ។

៤- បង្គាប់ឲ្យនាង សស បង់ប្រាក់ប្រដាប់ក្ដីចំនួន១% (មួយភាគរយ) នៃតម្លៃទ្រព្យដែលជាមរតកដែលបានចែកឲ្យទៅដើមចោទ(៦៤% នៃមរតករួម ) ។

៥- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្ដីបើកផ្លូវប្ដឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃនេះតទៅ ។

សាលក្រមនេះត្រូវបានឈ្មោះ សស ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងចុះថ្ងៃទី៣.៤.៩៦ លើចំណុចសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១៦-០២-៩៨ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខដើមចោទឈ្មោះ សស ទសប កំបាំងមុខ ឈ្មោះ សស ឈផល និងចំពោះមុខចុងចម្លើយដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣-០៤-៩៦ របស់ឈ្មោះ សស ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធន៍សាលក្រមរដ្ឋប្បវេណីលេខ១៦(ក) ចុះថ្ងៃទី៦.៣.៩៦ របស់តុលាការ ខេត្តកណ្តាលចោលជាអាសារបង់។

៣- បដិសេធន៍ពាក្យបណ្តឹងសុំបែងចែកមរតករបស់ដើមចោទចុះថ្ងៃទី០១-០៨-៩៥ ចោលជាអាសារបង់ ។

៤- ប្រគល់ដីទំនាស់ស្ថិតនៅភូមិជ្រោយដង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាលឲ្យឈ្មោះស៊ិនសុន កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៥- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍១៣០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊្នឹង២៥៥០រៀល រង្វាន់ក្រឡាបព្ទកាន់ហើបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការចំនួន ៥០០០៛ សរុប១៣០០៛ ។ កាលបើហួសបណ្តឹង សាទុក្ខបង្គាប់ឲ្យចុងបណ្តឹងឧទ្ធរណ៍រួមគ្នាបង់ប្រាក់១៣០០០៛ នេះទៅដើមបណ្តឹងឧទ្ធរណ៍វិញ និងបង្គាប់ឲ្យបង់ពន្ធសមាមាត្រ១%លើតម្លៃដីទំនាស់ ។ ប្រាក់ពន្ធនេះ៨០% ត្រូវបង់ចូលថវិការដ្ឋនិង២០% ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស។

៦- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោនមុខដើមចោទឈ្មោះ សស ទសប កំបាំងមុខឈ្មោះ សស ឈផល និងចំពោះមុខចុងចំលើយ ។

បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះត្រូវបានឈ្មោះ សស និងឈ្មោះ ទសប ប្តឹងសាទុក្ខតាមបណ្តឹងលេខ៦២ ចុះថ្ងៃទី២៤ . ០៣.៩៨ មិនសុខចិត្តពីសេចក្តីសម្រេចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ របស់ឈ្មោះ សស និងឈ្មោះ ទសប ។

បានឃើញសារណាតបចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះ សស ។

បានស្តាប់របាយការណ៍របស់ចៅក្រមប្រាយការណ៍

បានស្តាប់សចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: សាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១៦-០២-៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសុំម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោក សស ជាដើមចោទ និង ជាដើមបណ្តឹងសាទុក្ខបានឆ្លើយនាពេលសវនាការថា: សាលាឧទ្ធរណ៍កាត់សេចក្តីពុំត្រឹមត្រូវព្រោះថាដីនេះជាដីកេរ្តិ៍របស់ឪពុកម្តាយខ្លួនពិតប្រាកដក្រោយឆ្នាំ១៩៧៩ ឪពុកម្តាយខ្លួនបានមករស់នៅលើដីនេះគឺដីខាងត្បូង និងខាងជើងថ្នល់ ។ នៅឆ្នាំ១៩៩២ ឪពុកខ្លួនបាន ស្លាប់ម្តាយខ្លួនក៏ហៅកូនៗមកវាស់ដីចែកនៅពេលនោះឈ្មោះ ស មិនបានជំទាស់ទេមកដល់ពេលនេះគាត់រំលោភសិទ្ធិជំទាស់ ឈប់ឲ្យដីនេះមកពួកខ្លួនវិញ។ សូមតុលាការមេត្តាជួយវិនិច្ឆ័យឲ្យខ្លួនផងព្រោះដីនេះឪពុកខ្លួនបានបែងចែកតាំងពីគាត់មិនទាន់ស្លាប់ម្ល៉េះ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ទសប ជាដើមចោទ និងជាដើមបណ្តឹងសាទុក្ខបានឆ្លើយនាពេលសវនការថា ដីនេះខ្លួនត្រូវបានចំណែកពីគាត់ដែរដោយប្តីខ្លួនគាត់បានស្លាប់ហើយ។ នៅពេលចែកដីនោះគឺឪពុកម្តាយក្មេកខ្លួនចែកឲ្យកូន៣នាក់ គឺដីខាងមាត់ទន្លេតែពេលនេះឈ្មោះ ស នេះគាត់មិនព្រមឲ្យដីនោះមកខ្លួនទេ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី សស ជាចុងចម្លើយ និងជាចុងបណ្តឹងសាទុក្ខបានឆ្លើយនាពេលសវនាការថា ដីនេះគឺជាដីរដ្ឋចែកឲ្យខ្លួនមិនមែនជាដីកេរ្តិ៍ឪពុកម្តាយទេខ្លួន រស់នៅលើដីនេះតាំងពីឆ្នាំ១៩៧៩ មកជាមួយឪពុកម្តាយខ្លួន ហើយខ្លួនជាអ្នកគ្រប់គ្រងឪពុកម្តាយខ្លួន ។ ហេតុដែលខ្លួនគ្មានឈ្មោះក្នុងប័ណ្ណគ្រួសារព្រោះប័ណ្ណគ្រួសារ នោះបានបាត់នៅពេលខ្លួនរវល់ធ្វើបុណ្យសព្វថ្មីពុកខ្លួនចោរវាបានលួចយកទៅ ហើយខ្លួនពុំសូវចេះដឹងអ្វី ផងក៏ពុំបានធ្វើថ្មី ដែរ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៦២ ចុះថ្ងៃទី២៤.០៣.៩៨ របស់អ្នកស្រី ទសប និង លោក សស ធ្វើឡើងក្នុង កំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលា ជំរះក្តី ។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សម្រេចលើកបណ្តឹងទាមទារចែកមរតករបស់ដើមចោទចោល ដោយសំអាងទៅលើសាក្សី និងម្តាយនៃគូភាគី ដែលថាដីនេះរដ្ឋអំណាចបានចែកឲ្យអ្នកស្រី សស និងស្វាមីនៅឆ្នាំ១៩៩២ នោះជាការភ័ន្តច្រឡំពី ព្រោះថាតាមការស៊ើបអង្កេតនៅតុលាការថ្នាក់ក្រោម ដីដែលជាកម្មវត្ថុ នៃការប្តឹងសុំបែងចែកនេះជាដីដែលសពលោក សអ និងអ្នកស្រីនៅ កើត ដែលត្រូវបានរដ្ឋអំណាចបែងចែកឲ្យ និងគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩-៨០ មកម្ល៉េះ ។ហើយអ្នកស្រី សស និងស្វាមីទើប

តែមករស់នៅលើដីនេះនៅឆ្នាំ១៩៩០ ប៉ុណ្ណោះហើយចាប់ពីឆ្នាំ១៩៩០ មកក៏ពុំមានភស្តុតាងណាបញ្ជាក់ថារដ្ឋអំណាចបានធ្វើការបែងចែកដីទៀតដែរ ។

យល់ឃើញថា ទោះជាលោក សអ ទទួលមរណៈភាពហើយក្តី ក៏ភាគីនៅរស់គឺអ្នកស្រីនៅ កើត ពុំមានសិទ្ធិចាត់ចែងទ្រព្យសម្បត្តិរួមតែម្នាក់ឯងដែរ គឺត្រូវបែងចែកសិទ្ធិចាត់ចែងជាពីរចំណែកស្មើគ្នា ផ្នែកដែលត្រូវបានទៅអ្នកស្រីនៅ កើត អ្នកស្រីរូបនេះអាចចាត់ចែងតាមឆន្ទៈរបស់អ្នកស្រី ឯចំណែកដែលត្រូវបានទៅសពលោក សអ ត្រូវបានជាមរតក នៃទាយាទទាំងអស់រួមទាំងអ្នកស្រី សស ផង ។ ម្យ៉ាងទៀតសាលដីកាលេខ៤៦ ចុះថ្ងៃទី១៦០.២.៩៨ របស់សាលាឧទ្ធរណ៍ ជាសាលដីកាកំបាំងមុខឈ្មោះ សស និង ឈផល ហើយពុំមានឯកសារណាមួយបញ្ជាក់ថា សាលាឧទ្ធរណ៍បានជូនដំណឹងពីសាលដីកានេះដល់ឈ្មោះ ឈផល ទេ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១៦.០២.៩៨ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះមាន ការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ ទនិច្ឆ័យសេចក្តចំពោះមុខគូក្ត

១- ទទួលបណ្តឹងសាទុក្ខលេខ៦២ មុនថ្ងៃទី២៤.៣.៩៨ របស់អ្នកស្រី ទសប និងលោក សស ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១៦.០២.៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៧៥ ចុះថ្ងៃទី២៣.៩.៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០រៀល ដែលដើមចោទបានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន១៥០០០រៀល សរុប១៩០០០រៀល ហើយតម្រូវឲ្យចុងចម្លើយសង ប្រាក់ចំនួន១៩០០០រៀល នេះទៅដើមចោទវិញ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ ។